## សំបុត្រនៅថ្ងៃបុណ្យប៉ាស្កា
## ពី ម៉ីត្រូប៉ូលីត សែប្រហ្គី នៃទីក្រុងសិង្ហបុរី និងតំបន់អាស៊ីអាគ្នេយ៍
## ទៅកាន់គ្រូបរិស្សុទ្ធ បូជាចារ្យ ឌីខិន សង្ឃ និងដូនជី ទាំងអស់
## និងអ្នកមានជំនឿនៃព្រះសហគមន៍គ្រិស្តសាសនាអរតូដុក្សរុស្ស៊ីទាំងអស់
## នៅអាស៊ីអាគ្នេយ៍

**បរិស្សុទ្ធជាទីស្រឡាញ់ បូជាចារ្យនិងឌីកុនជាទីគោរពទាំងអស់**
**ព្រះសង្ឃ និង ដូនជីដែលស្រឡាញ់ព្រះជាម្ចាស់ទាំងអស់**
**និងបងប្អូនជាទីគោរពរាប់អាន!**

**ព្រះគ្រីស្ទបានរស់ឡើងវិញ!**

ខ្ញុំសូមអបអរសាទរអស់ពីដួងចិត្តក្នុងពិធីបុណ្យប៉ាស្កា ដ៏ទេវភាពនិងដ៏មានអំណរដែលបានបើកផ្លូវទៅកាន់អមតៈភាពសម្រាប់មនុស្សគ្រប់គ្នា។

*រដូវផ្ការីកនៃសេចក្តីជំនឿបានមកដល់ ដោយបានបណ្តេញភាពសោកសៅនៃតណ្ហា និងព្យុះនៃគំនិត* (វេនថ្វាយបង្គំនៅថ្ងៃព្រហស្បតិ៍នៃសប្តាហ៍ទី ២ បន្ទាប់ពីបុណ្យប៉ាស្កា) ហើយបំភ្លឺយើងជាមួយនឹងពន្លឺដ៏អស្ចារ្យនៃការរស់ឡើងវិញ។ ព្រះអម្ចាស់ដែលស្រឡាញ់ការបង្កើតរបស់ទ្រង់ច្រើនជាងម្តាយម្នាក់ស្រឡាញ់កូន បានឡើងលើឈើឆ្កាងសម្រាប់យើង ហើយបានយកឈ្នះសេចក្តីស្លាប់ ដើម្បីអោយអ្នកជឿគ្រប់រូបអាចក្លាយជាអ្នកស្នងមរតកទៅកាន់ជីវិតអស់កល្បជានិច្ច។ បើប្រៀបធៀបទៅនឹងពរជ័យដែលបានសន្យាដោយព្រះគ្រីស្ទ បើប្រៀបធៀបទៅនឹងសេចក្តីអំណរនៃការនៅជាមួយទ្រង់ ទុក្ខព្រួយ និងការភ័យខ្លាចនៅលើផែនដី បញ្ហា និងការសាកល្បងផ្សេងៗ ក្លាយជាមិនសំខាន់ លើសពីនេះទៅទៀត ព្រះគង់នៅជាមួយយើងក្នុងកាលៈទេសៈណាក៏ដោយ។

តើមានអ្វីដែលអាចជាការរីករាយសម្រាប់អ្នកមានជំនឿ ជាងការដឹងថាគេជបុត្រដ៏ ជាទីស្រឡាញ់របស់ព្រះអម្ចាស់ ហើយព្រះហស្តរបស់ព្រះវរបិតាតែងតែបើកចំហចំពោះគេ! ព្រះគ្រីស្ទដែលត្រូវបានគេឆ្កាងនិងមានព្រះជន្មរស់ឡើងវិញ គឺមិនឆ្ងាយប៉ុន្មានទេ៖ ទ្រង់មិនត្រឹមតែមិនចាកចេញពីយើងប៉ុណ្ណោះទេ ប៉ុន្តែទ្រង់បានបង្កើតយើងជាអ្នកចូលរួមក្នុងរូបកាយ និងព្រះ

លោហិតរបស់ទ្រង់ ព្រះវិហារដ៏វិសុទ្ធនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលពីនោះ *រាល់អ្នកប្រព្រឹត្តអំពើអាក្រក់ រាល់តណ្ហារត់ចេញដូចគេចពីភ្លើង* (ការអធិស្ឋានបន្ទាប់ពីការរួបរួមដ៏វិសុទ្ធនៃ សត្ត ស៊ីមែអូន មេតាហ្វ្រាស្ត)។

យើងបានទទួលពីព្រះជាម្ចាស់នូវភាពពេញលេញនៃសេចក្តីស្រឡាញ់ ហើយវាជាកាតព្វកិច្ចដ៏ពិសិដ្ឋរបស់យើងក្នុងការចែកចាយសេចក្តីស្រឡាញ់នេះជាមួយអ្នកជិតខាងរបស់យើង ហើយត្រូវតែតែងតែអោយវាបានដឹកនាំនៅក្នុងជីវិតរបស់យើង។ ចូរពេលគេក្រឡេកមកមើលយើង សូមអោយអ្នកជឿសរសើរតម្កើង និងអរព្រះគុណព្រះជាម្ចាស់ ហើយអ្នកដែលមិនជឿបែរមករកទ្រង់ ដោយប្រាថ្នាចង់ក្លាយជាមនុស្សភ្លឺស្វាង និងរីករាយដូចពួកគ្រីស្តបរិស័ទ។

សូមព្រះអង្គសង្គ្រោះដែលបានរស់ឡើងវិញ ប្រទានដល់អ្នកទាំងអស់គ្នានូវកម្លាំងខាងវិញ្ញាណ និងខាងរាងកាយ សន្តិភាព និងសេចក្តីអំណរ ភាពរឹងមាំខាងវិញ្ញាណ និងសុខុមាលភាពគ្រប់បែបយ៉ាង ចូរទ្រង់ពង្រឹងអ្នកនៅក្នុងកិច្ចការ និងអំពើល្អរបស់អ្នក ដើម្បីឲ្យព្រះនាមដ៏វិសុទ្ធរបស់ទ្រង់ត្រូវបានលើកតម្កើងគ្រប់សម័យកាល។ អាម៉ែន។

*ម៉ីត្រូប៉ូលីត នៃទីក្រុងសឹង្ហបុរី និងតំបន់អាស៊ីអាគ្នេយ៍*

*អភិបាលនៃតំបន់អាស៊ីអាគ្នេយ៍*